Community First Choice

# ជម្រើសដំបូងសហគមន៍ ជម្រើសសេវាកម្ម

## អំពីសេវាកម្ម CFC

សេវាកម្មដែលមានរាយទីនេះត្រូវបានផ្តល់ជូនតាមរយៈ កម្មវិធីជម្រើសដំបូងសហគមន៍ (CFC) សម្រាប់អតិថិជនមានសិទ្ធិទទួល។

### ការថែទាំផ្ទាល់ខ្លួន

សេវាកម្មការថែទាំផ្ទាល់ខ្លួនផ្តល់ជំនួយជាមួយកិច្ចការរៀងរៃ ដូចជាការងូតទឹក ការស្លៀកពាក់ ឬការគ្រប់គ្រងការប្រើប្រាស់ឱសថរបស់អ្នក។ ប្រសិនបើអ្នកមានសិទ្ធិទទួល អ្នកជ្រើសអ្នកផ្តល់ការថែទាំដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ម្នាក់។ DSHS ចំណាយឱ្យសម្រាប់ការពិនិត្យ និងបណ្តុះបណ្តាលអ្នកផ្តល់ការថែទាំមូលដ្ឋានសម្រាប់អ្នកផ្តល់ការថែទាំដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។

អ្នកអាចទទួលសេវាថែទាំផ្ទាល់ខ្លួនក្នុងផ្ទះ ឬក្នុងសហគមន៍របស់អ្នក ប្រសិនបើអ្នករស់នៅក្នុង ៖

- ✓ ក្នុងផ្ទះរបស់អ្នក
- ✓ ផ្ទះគ្រួសារមនុស្សពេញវ័យ
- ✓ មណ្ឌលជំនួយការរស់នៅ

### ការបណ្តុះបណ្តាលការគ្រប់គ្រងអ្នកផ្តល់ការថែទាំ

អ្នកផ្តល់ការថែទាំដែលបានបង់ប្រាក់របស់អ្នកគឺជាផ្នែកសំខាន់នៃក្រុមគាំទ្ររបស់អ្នក។ អ្នកគ្រប់គ្រងទម្លាប់ជាប្រចាំរបស់អ្នកផ្តល់ការថែទាំរបស់អ្នក។ ការបណ្តុះបណ្តាលគឺអាចរកបានដែលពន្យល់ពីរបៀបជ្រើស គ្រប់គ្រង និងបដិសេធអ្នកផ្តល់ការថែទាំ។

### ការថែទាំធូរស្បើយ

អ្នកផ្តល់ការថែទាំធូរស្បើយអាចត្រូវបានប្រើដើម្បីឱ្យអ្នកផ្តល់ការថែទាំជាប្រចាំរបស់សម្រាក ឬដើម្បីបោះជំហានបើអ្នកផ្តល់ការថែទាំជាប្រចាំឈឺ ឬមិនអាចធ្វើការបាន។ អ្នកកំណត់ប៉ុន្មានម៉ោងថែទាំផ្ទាល់ខ្លួនដែលបានអនុញ្ញាតរបស់អ្នក ដែលអ្នកចង់ឱ្យអ្នកផ្តល់ការថែទាំធូរស្បើយរបស់អ្នកមកធ្វើការ។

### ការបណ្តុះបណ្តាលការទទួលបានជំនាញ

ការបណ្តុះបណ្តាលគឺអាចរកបានសម្រាប់អ្នកដើម្បីក្លាយជាឯកសារាជ្ញជាមួយកិច្ចការថែទាំផ្ទាល់ខ្លួនជាប្រចាំរបស់អ្នក។ អ្នកអាចប្រើម៉ោងថែទាំផ្ទាល់ខ្លួនខ្លះ ឬការកម្រិតប្រចាំឆ្នាំនៃឆ្នាំសារពើពន្ធរបស់រដ្ឋរបស់អ្នកក្នុងការទិញការបណ្តុះបណ្តាលជំនាញទិញ។ នេះអនុញ្ញាតឱ្យអ្នកផ្តល់ការថែទាំបង្រៀនអ្នកពីរបៀបធ្វើកិច្ចការថែទាំផ្ទាល់ខ្លួន។ អ្នកផ្តល់ការថែទាំដែលបានបង់ប្រាក់របស់អ្នកអាចជួយជាមួយកិច្ចការខាងក្រោម ៖

- ការចម្អិន និងការរៀបចំអាហារ
- ការដើរទិញទំនិញ
- កិច្ចការថែរក្សាផ្ទះ
- ការបោកខោអាវ
- ការងូតទឹក (មិនរាប់បញ្ចូលសកម្មភាពផ្ទេរណាមួយ)
- ការស្លៀកពាក់
- ការលាបថ្នាំបំបាត់ក្លិន
- ការលាងដៃ និងមុខ
- ការលុបលាងមុខ ការសិតសក់ ការចាប់ម្ជុដសក់
- ការលាបគ្រឿងតុបតែងមុខ
- សិក្ខាការការជាមួយឡាមអគ្គិសនី
- ការដុសធ្មេញ ឬការថែទាំក្រាសធ្មេញពាក់
- ការថែទាំភាពសមស្លួន

## បច្ចេកវិទ្យាជំនួយ

បច្ចេកវិទ្យាជំនួយ រួមទាំងបរិក្ខារ និងធាតុផ្សេងទៀត អាចជួយអ្នកបញ្ចប់កិច្ចការដោយគ្មានជំនួយពីបុគ្គលផ្សេងទៀត ឬដើម្បីឯករាជ្យជាមួយកិច្ចការប្រចាំថ្ងៃ។

ដើម្បីទទួលបានបច្ចេកវិទ្យាជំនួយ អ្នកប្រហែលត្រូវការការវាយតម្លៃជំនាញលើធាតុអ្វីដែលល្អបំផុតសម្រាប់អ្នកដើម្បីបង្កើនឯករាជ្យភាពរបស់អ្នក។ អ្នកជំនាញនឹងណែនាំបច្ចេកវិទ្យាត្រឹមត្រូវ និងអាចជួយអ្នកស្វែងយល់ពីរបៀបប្រើវា។ បច្ចេកវិទ្យាជំនួយត្រូវបានផ្តល់ដោយប្រើការកម្រិតប្រចាំឆ្នាំនៃឆ្នាំសារពើពន្ធរដ្ឋ។

## ប្រព័ន្ធការឆ្លើយតបបន្ទាន់ផ្ទាល់ខ្លួន (PERS)

PERS គឺជាឧបករណ៍អេឡិចត្រូនិចមួយដែលអ្នកពាក់បានភ្ជាប់តាមរយៈទូរស័ព្ទដែលអនុញ្ញាតឱ្យអ្នកទទួលជំនួយក្នុងគ្រាមានអាសន្ន។ នៅពេលបានធ្វើឱ្យសកម្ម បុគ្គលិកនៅមណ្ឌលឆ្លើយតប នឹងតាមដានទិសដៅដែលអ្នកបានផ្តល់ដើម្បីទូរស័ព្ទរកជំនួយ។

លើសពីនេះ បន្ថែមលើសេវាកម្មដែលអាចរកបានដើម្បីមាន PERS របស់អ្នកត្រូវបានបំពាក់ជាមួយការរកឃើញធ្លាក់ចុះ ឧបករណ៍កំណត់ទីតាំង GPS ឬប្រព័ន្ធគ្រប់គ្រងការប្រើប្រាស់ឱសថ។

អ្នកគ្រប់គ្រងសំណុំរឿងរបស់អ្នកនឹងជួយកំណត់ថាតើអ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ប្រព័ន្ធទាំងនេះឬយ៉ាងណា។

ប្រសិនបើអ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ឈុត PERS ស្តង់ដារមួយត្រូវបានរួមបញ្ចូលក្នុងកញ្ចប់អត្ថប្រយោជន៍ CFC របស់អ្នក។ សេវាបន្ថែមនឹងត្រូវបានគិតប្រាក់ទៅតាមការកម្រិតប្រចាំឆ្នាំនៃឆ្នាំសារពើពន្ធរដ្ឋ។

## សេវាផ្ទាស់ប្តូរសហគមន៍

សេវាផ្ទាស់ប្តូរសហគមន៍អាចជួយអ្នកផ្ទាស់ទីពីបរិយាកាសស្ថាប័នមួយទៅជាសហគមន៍។ អ្នកអាចជ្រើសរើសផ្ទាស់ទីទៅផ្ទះខ្លួនឯង ផ្ទះគ្រួសារមនុស្សពេញវ័យ ឬមណ្ឌលជំនួយការរស់នៅជាមួយនឹងការគាំទ្រផ្សេងៗ។

ដើម្បីស្នើសុំសេវាកម្មផ្សេងៗ សូមទាក់ទងអ្នកគ្រប់គ្រងសំណុំរឿង DDA របស់អ្នក។ ប្រសិនបើអ្នកបច្ចុប្បន្នមិនកំពុងទទួលបានសេវាកម្មដែលបង់ប្រាក់មួយទេ អ្នកអាចទូរស័ព្ទទៅការិយាល័យក្នុងស្រុក ឬចូលមើល www.dshs.wa.gov/dda/service-and-information-request.

Washington State Department of Social & Health Services

*Transforming lives*

DSHS-22-1616 CA (Rev. 9/19) Cambodian